**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំឆ្នាំ២០១៣

*នៅក្នុងឆ្នាំ២០១៣នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅៈ*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បានៈ

*-ទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០២លើក*

*-អញ្ជើញចូលរួមព្រះរាជពិធីរំកិល ដង្ហែ ថ្វាយផ្កាខ្លឹមចន្ទ និងថ្វាយព្រះភ្លើង ព្រះបរមសព ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជជាតិ បូរណភាព ទឹកដី និងឯកភាពជាតិខ្មែរ*

*-អញ្ជើញចូលគាល់ថ្វាយព្រះពរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៦០ ព្រះវស្សា នៅព្រះបរមរាជវាំង*

*-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកសម័យប្រជុំលើកដំបូងរដ្ឋសភា នីតិកាលទី៥ ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានរដ្ឋសភា*

*-អញ្ជើញចូលរួមក្នុងព្រះរាជពិធីថ្វាយព្រះរាជកុសលព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបរមរតនកោដ្ឋ គម្រប់ខួបមួយឆ្នាំនៃការយាងចូលទិវង្គត នៅព្រះទីនាំងមហាមន្ទីរ ក្នុងព្រះបរមរាជវាំង*

*-អនុញ្ញាតឲ្យគណៈប្រតិភូពីប្រទេសនានាចូលជួបសវនាការ និងសម្តែងការគួរសម ចំនួន០៤លើក*

*-ទទួលគ្រឿងឥស្សរិយយស* Grand Cordon of the Order of the Rising Sun

នៃព្រះចៅអធិរាជជប៉ុន

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីចែកអំណោយ និងសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញចូលរួមជាអធិបតីក្នុងពិធីបុណ្យ និងពិធីផ្សេងៗចំនួន០៧លើក

-ចុះហត្ថលេខាលើព្រះរាជក្រម ព្រះរាជក្រឹត្យចំនួន៧៤ និងលិខិតផ្សេងៗចំនួន២៧៤លិខិត ។

**១.២ ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ ព្រឹទ្ធសភា បានៈ**

-ទទួលភារកិច្ចជាប្រធានស្ដីទីព្រឹទ្ធសភាចំនួន០៦លើក

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៨លើក កិច្ចប្រជុំពេញអង្គ និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០៨លើក

-អញ្ជើញចុះបំពេញការងារនៅមូលដ្ឋានរាជធានី-ខេត្តចំនួន៦៥លើក

-អនុញ្ញាតឲ្យគណៈប្រតិភូពីប្រទេសនានាចូលជួបសវនាការ និងសម្ដែងការគួរសមចំនួន០៦លើក

-អញ្ជើញចូលរួមជាកិត្តិយសជាមួយសង្គមស៊ីវិលចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសតាមការអញ្ជើញរបស់ឯកអគ្គរដ្ឋទូតនានា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាចំនួន០៧លើក

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងកម្មវិធីផ្សេងៗចំនួន៤២លើក

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២៣៦ច្បាប់ ។

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បានៈ**

-អញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៨លើក និងចូលរួមប្រជុំពេញអង្គ និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០៧លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី១ ព្រឹទ្ធសភា

-អញ្ជើញចូលរួមប្រជុំជាមួយក្រុមសមាជិក - សមាជិកាព្រឹទ្ធសភាមណ្ឌលភូមិភាគទី៣

-អញ្ជើញចូលរួមប្រជុំការងារសមាគមមិត្តភាពកម្ពុជា-ចិន

-អញ្ជើញចូលរួមប្រជុំសមាជិក-សមាជិកាព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំដឹកនាំគណៈប្រតិភូទៅចូលរួមសន្និបាតAIPA លើកទី៣៤ នៅប្រទេសប្រ៊ុយណេ ចំនួន០២លើក និងបានអញ្ជើញដឹកនាំសមាជិក-សមាជិកាព្រឹទ្ធសភាចូលរួមមហាសន្និបាត នៅប្រទេសប្រ៊ុយណេ តាមការកំណត់

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាទៅបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ក្នុងឱកាសអបអរខួបអនុស្សាវរីយ៍លើកទី៥៥ នៃថ្ងៃបង្កើតទំនាក់ទំនងការទូតកម្ពុជា-ចិន

-អនុញ្ញាតឲ្យភ្ញៀវជាតិ និងអន្តរជាតិចូលជួបសម្តែងការគួរសម និងពិភាក្សាការងារចំនួន០៨លើក

-អញ្ជើញជាអធិបតី និងជាកិត្តិយសក្នុងអង្គសិក្ខាសាលា សន្និសីទ សន្និបាត និងពិធីផ្លូវការផ្សេងៗចំនួន៣៦លើក

-អញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិក-សមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ នៅក្នុងខេត្តកណ្តាល ព្រៃវែង និងបាត់ដំបងចំនួន២៣លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧៩៥ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ និងប្រជុំពេញអង្គព្រឹទ្ធសភា

បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៨លើក ប្រជុំវិសាមញ្ញចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៦លើក និងបានពិនិត្យឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន២៤ដែលព្រឹទ្ធសភាទទួលបានពីរដ្ឋសភា។

## ៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងឆ្នាំ២០១៣នេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៣.១ មុខងារនីតិកម្ម

គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន២៤។

### ៣.២ មុខងារត្រួតពិនិត្យ

បានជួបសវនាការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្លឹបអ្នកកាសែតកម្ពុជា និងវិទ្យាស្ថានសភាកម្ពុជាចំនួន១០លើក ដើម្បីស្វែងយល់អំពីលទ្ធផលការងារដែលពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ ដែលក្រសួង ស្ថាប័ននានា របស់រដ្ឋាភិបាល

និងកំពុងអនុវត្ត

**៣.៣ មុខងារតំណាង**

-ទទួលពាក្យបណ្តឹងចំនួន៥៤ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធបានចំនួន៣៦បណ្តឹង ទទួលលិខិតឆ្លើយតបពីលទ្ធផលនៃការដោះស្រាយពីស្ថាប័នមានសមត្ថកិច្ចចំនួន១១បណ្តឹង តម្កល់ទុកមិនចាត់ការចំនួន១២បណ្តឹង និងដោះស្រាយបញ្ចប់បានចំនួន០២បណ្តឹង ។

-បានធ្វើវេទិកាសាធារណៈ ចំនួន៣លើក ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋនៅខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ ខេត្តព្រះសីហនុ និងខេត្តរតនគិរី ស្តីពីការយល់ដឹង និងការចាត់តាំងការអនុវត្តន៍តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយេនឌ័រ និងចុះជួបសំណេះសំណាល ចែកអំណោយដល់ប្រជាពលរដ្ឋរងគ្រោះមហន្តរាយដោយទឹកជំនន់ចំនួន៩០០គ្រួសារ នៅខេត្តកណ្តាល កំពង់ចាម ក្រចេះ ស្ទឹងត្រែង និងខេត្តរតនគិរី ។

-សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន ១៥៣៨លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ចែកប័ណ្ណកម្មសិទ្ធដីធ្លី ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំនានា និងពិធីផ្សេងការផ្សេងៗសរុបចំនួន៩៣៩លើក ។

**៣.៤ មុខងារព័ត៌មាន**

-សមាជិក-សមាជិកា គណៈកម្មការនានារបស់ព្រឹទ្ធសភាបានចុះបំពេញបេសកកម្មតាមបណ្តាខេត្តក្រុងចំនួន១៤លើក ដើម្បីស្វែងរកព័ត៌មានអំពីការអនុវត្តច្បាប់ គម្រោងអភិវឌ្ឍនានាការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការប្រើប្រាស់ថវិកាថ្នាក់ក្រោមជាតិ តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ អនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ គោលនយោបាយភូមិ-ឃុំមានសុវត្ថភាព ការងារយេនឌ័រ សុខភាពសាធារណៈ ពិនិត្យស្ថានភាពទឹកជំនន់ និងវិស័យផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ ។

**៤.កិច្ចសហប្រតិបត្តិការអន្តរជាតិ**

*-សមាជិក-សមាជិកាគណៈកម្មការនានារបស់ព្រឹទ្ធសភាចំនួន៤០រូប បានអញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត វេទិកា និងពិធីផ្សេងៗ នៅប្រទេសចិន វៀតណាម ឡាវ ថៃ ទួរគី សហព័ន្ធរុស្ស៊ី អូស្ត្រាលី កាណាដា សាធារណរដ្ឋអេក្វាឌ័រ ម៉ូណាកូ បារាំង ស្វីស ជប៉ុន កូរ៉េ ប៊្រុយណេ និងឥណ្ឌូនេស៊ី ។*

*រាជធានីភ្នំពេញ ថ្ងៃទី៣១ខែឧ ឆ្នាំ២០១៣*

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

*ចម្លងជូនៈ*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*